បេឡាជាតិសន្តិសុខសង្គម
National Social Security Fund

ព្រឹត្តិបត្រព័ត៌មានបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. ឆ្នាំទី ១០

## លេខ ២៩ ឆ្នាំ២០២០



ធានាសន្តិសុខប្រាក់ចំណូល

រួមចំណែកកាត់បន្ថយភាពក្រីក្រ

លើកកម្ពស់ស្ថិរភាពសង្គម

ទំនាក់ទំនងបន្ទាន់

**១២៨៦**

**២៤ម៉ោង/៧ថ្ងៃ**

# ព្រឹត្តិបត្រព័ត៌មាន ប.ស.ស.

## មាតិកា




០១ សម្តេចក្រឡាហោម កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ..........០១

០២ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិង.............០៣

០៣ ឯកឧត្តម អ៊ុក សមវិទ្យា អញ្ជើញប្រគល់រង្វាន់ដោយផ្ទាល់............០៦

០៤ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីរបប........០៧

០៥ ឯកឧត្តម អ៊ុក សមវិទ្យា ទទួលជួបពិភាក្សាការងារជាមួយ............០៩

០៦ ករណីសន្លប់ និងករណីគ្រោះថ្នាក់ចរាចរណ៍របស់បងប្អូន............ ១១

០៧ ឯកឧត្តម អ៊ុក សមវិទ្យា បានដឹកនាំគណៈប្រតិភូទៅចូលរួម..........១៤

០៨ ឯកឧត្តម អ៊ុក សមវិទ្យា កោតសរសើរពីនារី ប.ស.ស. ...............១៦

០៩ ប.ស.ស.នៅបន្តខិតខំធ្វើយ៉ាងណាបម្រើសេវាសន្តិសុខសង្គម.....១៨

១០ បេឡាជាតិសន្តិសុខសង្គម នឹងដាក់ឱ្យអនុវត្តនូវ របបសន្តិសុខ.....២០

១១ កិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោងកិច្ចគាំពារ.............២២

១២ បេឡាជាតិសន្តិសុខសង្គម បន្តពង្រឹងការអនុវត្តរបបសន្តិសុខ.......២៤

១៣ អ្នកបើកបរយានយន្តដឹកកម្មករ និងបងប្អូនកម្មករ-កម្មការិនី.........២៦

១៤ ថ្នាក់ដឹកនាំ នៃបេឡាជាតិសន្តិសុខសង្គម ចំនួន២រូប ចូលរួម.......២៨

១៥ អាហារទាំងប៉ុន្មានប្រភេទនេះ ជាប្រភពនៃប្រូតេអ៊ីន...................២៩







## រចនាសម្ព័ន្ធព្រឹត្តិបត្រ

### ឯកឧត្តម អ៊ុក សមវិទ្យា
### នាយក ប.ស.ស.

| | |
|---|---|
| ចាងហ្វាង | ឯកឧត្តម ហេង សុផាន់ណារិទ្ធ |
| និពន្ធនាយក | លោក យ៉ាម យុទ្ធា |
| និពន្ធនាយករង | លោក យុន វិចិត្រ |
| | លោក វ៉ាន់ ចាន់ថន |
| លេខានិពន្ធ | កញ្ញា វ៉ាត់ ម៉ាលីកា |
| | លោក នាង ជូ |
| | លោក យន គន្ធា |
| | លោក អ៊ឹង លាងឆុង |
| ផ្នែកការីកុំព្យូទ័រ | លោក យង់ សុខន |
| | លោក អ៊ុង ស៊ីខឿ |



# សម្តេចក្រឡាហោម កោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការចុះផ្សព្វផ្សាយអប់រំច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្នុងឆ្នាំ២០១៩

**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងឡើងបែបនេះ នៅក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆ្នាំ២០១៩ នៅថ្ងៃអង្គារ ១២ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ។

**សម្តេចក្រឡាហោម** បានថ្លែងបន្ថែមថា៖ សម្តេចសូមកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ដែលបានរួមចំណែកយ៉ាងសំខាន់ ក្នុងការចុះផ្សព្វផ្សាយអប់រំច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកកន្លងមកនេះ ក្នុងនោះក៏មានស្ថាបន័បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ ដែលមានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតតែងតែចុះផ្សព្វផ្សាយអប់រំច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជូនដល់ អ្នកបើកបររថយន្តដឹកកម្មករ ពិសេសកម្មករនិយោជិត ក្នុងន័យឱ្យពួកគាត់ទាំងអស់បានយល់ដឹងកាន់តែច្បាស់អំពីសុវត្ថិភាពក្នុងការធ្វើដំណើរ ពិសេសគឺស្វែងយល់អំពីច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោកផងដែរ នេះគឺជាសកម្មភាព និងការចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចណ៍ឱ្យនៅកម្រិតទាប ស្របទៅតាមអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** " ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍" ។







គួរបញ្ជាក់ផងដែរថា៖ យោងតាមរបាយការណ៍របស់ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម នៅក្នុងឆ្នាំ២០១៩ កន្លងទៅថ្មីៗ នេះករណីគ្រោះថ្នាក់ចរាចរណ៍ ដែលកើតទៅលើបងប្អូនកម្មករនិយោជិតមានចំនួន ១៥៥៦លើក មានការថយចុះចំនួន ១៥៤លើក ស្មើនឹង ៩.៨៩% បើធៀបទៅនឹងឆ្នាំ ២០១៨ កន្លងមកនេះ។

យោងតាមរបាយការណ៍ ដែលបានឡើងដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបញ្ជាក់ឱ្យដឹងផងដែរថា មធ្យោបាយធ្វើដំណើរមានកំណើនចំនួន ៣៧% បច្ចុប្បន្នគឺជាប្រទេសមានយានយន្តសរុប ៥ ៣៣៨ ៣៩៤ គ្រឿង ក្នុងនោះ ម៉ូតូមានចំនួន ៤៥ ៥៥២ ២៤១ គ្រឿង - ស្មើនឹង៨0%និងរថយន្តគ្រប់ប្រភេទមានចំនួន ៧៨៣ ១៧៣ គ្រឿងស្មើនឹង ១៧% ដោយបានធ្វើឱ្យសកម្មភាពចរាចរណ៍នៅទូទាំងប្រទេសកាន់តែមានភាពមមាញឹក និងកាន់តែចង្អៀត។ ទន្ទឹមគ្នានេះ យើងសង្កេតឃើញថា គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកឆ្នាំ ២០១៩ មានការកើនឡើងចំនួន ៨៥៣លើក ស្មើនឹង២៦% ដែលអ្នកស្លាប់កើនឡើង ២២០នាក់ ស្មើនឹង ១២% និងអ្នករបួសកើនឡើងចំនួន ១ ៣៧១នាក់ ស្មើនឹង ២៩% នេះគឺជាតួលេខមួយគួរឱ្យព្រួយបារម្ភបំផុត។

**សម្តេចក្រឡាហោម** បានជម្រុញដល់ កម្លាំងសមត្ថកិច្ចចរាចរណ៍ផ្លូវគោក បង្កើនការចុះអនុវត្តច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងបង្កើនការយកចិត្តទុកដាក់ចំពោះសុវត្ថិភាពក្នុងការធ្វើដំណើរ និងបានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាចូលរួមអនុវត្តច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឱ្យបានទាំងអស់គ្នា ធ្វើយ៉ាងណាទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍ឱ្យនៅកម្រិតទាបបំផុត។









# ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះលទ្ធផលការងារដែល ប.ស.ស. សម្រេចបានក្នុងឆ្នាំ២០១៩ កន្លងមកនេះ

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** បានថ្លែងឡើង ក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅការងារបន្តឆ្នាំ ២០២០របស់បេឡាជាតិសន្តិសុខសង្គម ដែលបានរៀបចំឡើង នៅសាលប្រជុំ-សណ្ឋាគារតារាអ៊ែរផត រាជធានីភ្នំពេញ នាថ្ងៃអង្គារ ទី១៤ ខែមករាឆ្នាំ២០២០។

**ឯកឧត្តម**រដ្ឋមន្ត្រី បានថ្លែងបន្ថែមទៀតថា៖ ឯកឧត្តមសូមកោតសរសើរដោយស្មោះ ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាល មន្ត្រី-រាជការ បុគ្គលិក នៃបេឡាជាតិសន្តិសុខ-សង្គម និងក្រសួង ស្ថាប័ន អង្គភាព និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដែលបាន-ចូលរួមចំណែកក្នុងគ្រប់សកម្មភាព និងស្មារតីទទួលខុសត្រូវខ្ពស់ ជាចលករមួយយ៉ាងសំខាន់ ធ្វើឱ្យអង្គភាពមួយនេះ ទទួលបាននូវលទ្ធផលគួរជាទីមោទនៈរហូតមកដល់ពេលនេះ។

កន្លងមក ប.ស.ស. ធ្លាប់ទទួលបានពានរង្វាន់ឆ្នើមចំនួន ៤លើករួចមកហើយ ពីសមាគមសន្តិសុខសង្គមអាស៊ាន លើកទី(១) ពានរង្វាន់អង្គភាពឆ្នើម ក្នុងការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិ-ភ័យការងារ ប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅឆ្នាំ២០១៥ ពីសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសសឹង្ហបុរី លើកទី(២) ពានរង្វាន់ឆ្នើមស្តីពីការគ្រប-ដណ្តប់ផ្នែកការធានារ៉ាប់រងរបបសន្តិសុខ-សង្គម ប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅឆ្នាំ២០១៦ ពីសមាគមសន្តិសុខសង្គម-អាស៊ាន (ASSA) នៅប្រទេសហ្វីលីពីន លើកទី(៣) ទទួលបានពានរង្វាន់ ស្តីពីការផ្តល់សេវាល្អ សម្រាប់របបថែទាំសុខភាព-









នៅឆ្នាំ២០១៨ ពីប្រធានសមាគមសន្តិសុខសង្គមអាស៊ាន (ASSA) នៅប្រទេសវៀតណាម និងលើកទី(៤) ពានរង្វាន់ស្តីពីការផ្តល់សេវាធានារ៉ាប់រងសុខភាពសម្រាប់មន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជននៅឆ្នាំ២០១៩ (Health Care Scheme for Public Employees, Former Civil Servants, and Veterans) ពីប្រធានសមាគមសន្តិសុខសង្គមអាស៊ាននៅប្រទេសព្រុយនេ ។

ទាក់ទងទៅនឹងលទ្ធផលសម្រេចបាននៅក្នុងឆ្នាំ២០១៩ កន្លងមកនេះ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម បានបញ្ជាក់ឱ្យដឹងថា៖ ច្បាប់ស្តីពីរបបសន្តិសុខសង្គមថ្មី ត្រូវបានប្រកាសឱ្យប្រើប្រាស់រួចហើយ ដែលគ្របដណ្តប់ទៅលើការគាំពារចំនួន ៤ផ្នែក រួមមាន (១)ផ្នែកប្រាក់សោធន (២)ផ្នែកថែទាំសុខភាព (៣)ផ្នែកហានិភ័យការងារ និង (៤)ផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោម







ច្បាប់ស្ដីពីការងារ រួមទាំងបុគ្គលិកផ្លូវអាកាស នាវាសមុទ្រ និងអ្នកបម្រើក្នុងផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជន៍ផងដែរ។ បេឡាជាតិសន្តិសុខសង្គម កន្លងមកបាន នឹងកំពុងអនុវត្តនូវរបបសន្តិសុខសង្គម ចំនួន២ គឺផ្នែកហានិភ័យការងារ និង ផ្នែកថែទាំសុខភាព របបសន្តិសុខសង្គម ទាំងពីរនេះ បានគ្រប់ដណ្ដប់ទាំងកម្មករ និយោជិត និងមន្ត្រីសាធារណៈ។ ការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកនីមួយៗ នេះគឺមានសារៈសំខាន់ណាស់ក្នុងការ ចូលរួមចំណែកដើម្បីសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចជាតិ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល ជឿជាក់ថា នៅក្នុងឆ្នាំថ្មីនេះ មន្ត្រី និងបុគ្គលិកយើងពិតជាខិតខំសិក្សាស្វែងយល់ ពីគោលនយោបាយអនុវត្តរបបសន្តិសុខសង្គម ពីបណ្ដាប្រទេសក្នុងតំបន់ និង បណ្ដាប្រទេសជាដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីទទួលបានចំណេះដឹង និងបទពិសោធន៍ថ្មីៗ សម្រាប់បំពេញបន្ថែមលើ ការងារដែលមានស្រាប់ និងកែលម្អការ អនុវត្តរបបសន្តិសុខសង្គមរបស់យើឱ្យ កាន់តែប្រសើរឡើងថែមទៀត។

សូមបញ្ជាក់ថាៈ ពិធីសន្និបាតបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅការងារបន្តឆ្នាំ២០២០ របស់បេឡាជាតិសន្តិសុខសង្គមខាងលើប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីសំណាក់ **ឯកឧត្តមបណ្ឌិត អ៊ិតសំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយមានវត្តមានចូលពីតំណាងក្រសួង ស្ថាប័ន អង្គការ និង អង្គភាពពាក់ព័ន្ធនានាសរុបប្រមាណជាង ៣០០នាក់៕










# ឯកឧត្តម អ៊ុក សមវិទ្យា
## អញ្ជើញប្រគល់រង្វាន់ដោយផ្ទាល់ដល់អ្នកឆ្លើយសំណួរក្នុងកម្មវិធី “ខ្ញុំដឹងខ្ញុំឈ្នះ”

**ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់កិត្តិយស អញ្ជើញប្រគល់រង្វាន់ជូនដោយផ្ទាល់ដល់អ្នកឈ្នះរង្វាន់ទាំង ១៦នាក់ ក្នុងនោះអ្នកមកទទួលរង្វាន់ជាមួកសុវត្ថិភាព ៥នាក់ និងអាវយឺត ១១នាក់ នៅសណ្ឋាគារតារាអ៊ែរផត រាជធានីភ្នំពេញ នៅថ្ងៃអង្គារ ទី១៤ ខែមករា ឆ្នាំ២០២០ នៅក្នុងឱកាសនៃពិធីសន្និបាតបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅការងារបន្តឆ្នាំ២០២០។

កម្មវិធីខ្ញុំដឹងខ្ញុំឈ្នះ ត្រូវបានរៀបចំឡើងដោយ បេឡាជាតិសន្តិសុខសង្គម ក្នុងគោលបំណងដើម្បីឱ្យជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ មន្ត្រីសាធារណៈ និងសាធារណៈជនទូទៅបានយល់ដឹងពីគោលនយោបាយ នៃការអនុវត្តរបបសន្តិសុខសង្គម របស់បេឡាជាតិសន្តិសុខសង្គម តាមរយៈការប្រកួតប្រជែងឆ្លើយសំណួរនៅលើបណ្តាញសង្គមហ្វេសបុកផេកផ្លូវការរបស់បេឡាជាតិរបបសន្តិសុខសង្គម បានត្រឹមត្រូវ និងបានបំពេញគ្រប់តាមលក្ខខណ្ឌនៃកម្មវិធី។

សូមបញ្ជាក់ថា៖ កម្មវិធីនេះត្រូវបានដាក់ឱ្យដំណើរការនៅដើមខែធ្នូ ឆ្នាំ២០១៩ ដោយគិតរហូតមកដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ នេះ គឺក្រុមការងារបានធ្វើចំនួន ៤ វគ្គរួចមកហើយ ដែលមានអ្នកឈ្នះចំនួន ៤០ នាក់ ក្នុងនោះអ្នកឈ្នះរង្វាន់ជាមួកសុវត្ថិភាពចំនួន ២០ នាក់ និងអ្នកឈ្នះអាវយឺត ប.ស.ស. ចំនួន ២០ នាក់ នឹងបានកំពុងបន្តដាក់ឱ្យដំណើរនៃកម្មវិធីនេះបន្តទៀត៕



# កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

នៅថ្ងៃអង្គារ ៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ក្រុមការងារបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងអនុក្រឹត្យស្តីពី៖ "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ" ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គមព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំបេឡាជាតិសន្តិសុខសង្គម តំណាងស្ថាប័ននីតិប្បញ្ញត្តិ និងតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម នៅសាលប្រជុំ ប.ស.ស. រាជធានីនៅភ្នំពេញ។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល សង្ឃឹមជឿជាក់យ៉ាងមុតមាំថា៖ សមាជិកសមាជិការ ក្នុងអង្គប្រជុំទាំងអស់នឹងចូលរួមចំណែកយ៉ាងសកម្មដើម្បីផ្តល់ជាធាតុចូលជាច្រើនបន្ថែមទៀត ដើម្បីឱ្យការអនុវត្តរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជននៅកម្ពុជាកាន់តែមានលក្ខណៈល្អប្រសើរនឹងធានាបាននូវការទ្រទ្រង់ ស័ក្តិសិទ្ធភាព និងចីរភាពគ្រប់ជ្រុងជ្រោយ។





ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើឱ្យប្រទេសជាតិទាំងមូលមានសុខសន្តិភាព មានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិមានការរីកចម្រើន និងប្រកបដោយចីរភាព ហើយនេះគឺជាពេលវេលាល្អក្នុងការបង្កើតឱ្យមានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនថ្មីបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជាសម្រាប់វិស័យឯកជននៅកម្ពុជា ក្នុងគោលបំណងទំនុកបម្រុងជីវភាពប្រជាជនពេលចាស់ជរា ខ្វះលទ្ធភាពស្វែងរកប្រាក់ចំណូល ព្រមទាំងកាត់បន្ថយបន្ទុកចំណាយក្នុងគ្រួសារ និងទម្លាប់ចិញ្ចឹមតគ្នា។



**ឯកឧត្តម** ប្រតិភូ ក៏បានគូសបញ្ជាក់ផងដែរថា៖ ក្នុងនាម ប.ស.ស. ជាប្រតិបត្តិករទោលនៃវិស័យសន្តិសុខសង្គមកម្ពុជា បានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ចំនួន៥លើករួចមកហើយនឹងសម្រេចបានសេចក្តីព្រាងអនុក្រឹត្យស្តីពី៖ "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ" ដោយបញ្ញត្តិអំពីយន្តការ លក្ខខណ្ឌបែបបទ និងនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន អត្រាភាគទាន-អត្រាសមាច័យ ការទាមទារ និងការផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់វិស័យឯកជន៕





# ឯកឧត្តម អ៊ុក សមវិទ្យា ទទួលជួបពិភាក្សាការងារ ជាមួយ ភារៈធារី នៃស្ថានទូតសាធារណរដ្ឋហ្វីលីពីន ប្រចាំប្រទេសកម្ពុជា លើការអនុវត្តស្តីពីវិស័យសន្តិសុខសង្គម



នៅថ្ងៃសុក្រ ទី០៧ ខែកុម្ភៈឆ្នាំ២០២០ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានទទួលជួបពិភាក្សាការងារជាមួយ លោកស្រី Myca Magnolia M. FISCHER ភារៈធារី នៃស្ថានទូតសាធារណរដ្ឋហ្វីលីពីនប្រចាំប្រទេសកម្ពុជា លើការអនុវត្តស្តីពីវិស័យសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។



ក្នុងឱកាសនោះ **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលបានសំដែងនូវអំណរគុណចំពោះរដ្ឋាភិបាល ក៏ដូចជាប្រជាជនហ្វីលីពីន ដែលតែងតែជួយផ្តល់ការគាំទ្រដល់កម្ពុជា ពិសេសលើកិច្ចសហប្រតិបត្តិការទ្វេភាគីនៅក្នុងវិស័យសន្តិសុខសង្គម។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលបានរៀបរាប់អំពីសារបានខ្លះៗ ស្តីពីការអនុវត្តរបបសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបច្ចុប្បន្ន ប.ស.ស. បានកំពុងនឹងអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់វិស័យឯកជន ចាប់តាំងពីចុងឆ្នាំ ២០០៨ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់វិស័យឯកជន នៅឆ្នាំ២០១៦ និងសម្រាប់វិស័យសាធារណៈ (មន្ត្រីរាជការ) នៅឆ្នាំ ២០១៨។ ចំណែកឯ របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់វិស័យឯកជននឹងត្រូវអនុវត្តនាពេលដ៏ខ្លីខាងមុខនេះ។

ជាមួយគ្នានេះ **លោកស្រី** ភារៈធារីនៃស្ថានទូតសាធារណរដ្ឋហ្វីលីពីន បានលើកឡើងអំពីកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើររវាងរដ្ឋាភិបាលប្រទេសទាំងពីរលើគ្រប់វិស័យទាំងអស់ ដែលក្នុងនោះក៏មានកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខសង្គមផងដែរ ដែលកន្លងមកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) និងអង្គភាពធានារ៉ាប់រងសុខភាពហ្វីលីពីន (PhilHealth) បានចុះអនុស្សារណៈនៃការយោគយល់ស្តីពីភាពជាដៃគូរួមគ្នា កាលពីថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៨ កន្លងទៅ។

**លោកស្រី** បានបន្ថែមទៀតថា លោកស្រីនឹងជម្រុញស្ថាប័ន/អង្គភាពពាក់ព័ន្ធនឹងសន្តិសុខសង្គមរបស់ប្រទេសហ្វីលីពីន ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខសង្គមជាមួយ ប.ស.ស. ពិសេសលើរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ដែលពាក់ព័ន្ធនឹងចល័តភាពរបបសន្តិសុខសម្រាប់ពលករទេសន្តរប្រវេសន៍រវាងប្រទេសទាំងពីរផងដែរ៕










# ករណីសន្លប់ និងករណីគ្រោះថ្នាក់ចរាចរណ៍របស់បងប្អូនកម្មករនិយោជិត មានការថយចុះបើធៀបជាមួយឆ្នាំ២០១៨ ជាមួយនឹងឆ្នាំ២០១៩

នៅសាលប្រជុំធំ នៃបេឡាជាតិសន្តិសុខសង្គម នាថ្ងៃសុក្រ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២០នេះ ក្រុមការងារទប់ស្កាត់ករណីសន្លប់ និងបង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត ទ.ស.ប.ក. និងក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក. នៃបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅបន្តឆ្នាំ២០២០ របស់ខ្លួន ក្រោមអធិបតីភាព **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. ជាសមាជិកគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក និងជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត ស.ផ.ក. នៃបេឡាជាតិសន្តិសុខសង្គម។

បើយោងតាមរបាយការណ៍ប្រចាំឆ្នាំ ២០១៩ ដែលបានថ្លែងឡើងដោយ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយនៃបេឡាជាតិសន្តិសុខសង្គម បានថ្លែងឱ្យដឹងថា៖ កន្លងមកនេះ ក្រុមការងារ ទ.ស.ប.ក. បានចុះអង្កេត និងសិក្សាស្រាវជ្រាវករណីកម្មករនិយោជិតសន្លប់ ដើម្បីស្វែងរកមូលហេតុ និងចាត់វិធានការកែលម្អលើ រោងចក្រដែលមានកម្មករនិយោជិតសន្លប់មានចំនួន ១១រោងចក្រ និងកម្មករនិយោជិតសន្លប់ចំនួន ៨៣១នាក់ ក្នុងនោះស្រី ៨២២នាក់ ។បើប្រៀបធៀបនឹងឆ្នាំ២០១៨ គឺមានការថយចុះចំនួន ៦រោងចក្រ ស្មើនឹង ៣៥% និងកម្មករនិយោជិតសន្លប់ថយចុះចំនួន ១ ២៧៨នាក់ ស្មើនឹង ៦១% ភាគច្រើនកម្មករនិយោជិត-





ដែលរងគ្រោះ គឺបានផ្តើមចេញពីកម្មករនិយោជិតសន្លប់តែពីម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ប៉ុន្តែគឺបានឆ្លងនូវជំងឺស្ទេហ៍ហ្វូង។

**ឯកឧត្តម** ប្រធានការិយាល័យបានឱ្យដឹងបន្ថែមថា៖ មូលហេតុចម្បងៗដែលបណ្តាលឱ្យមានករណីសន្លប់កើតមានឡើង រួមមានដូចជា បញ្ហាចិត្តសាស្ត្រសង្គម ៣៩% បញ្ហាគីមី ១៨% បញ្ហារូបសាស្ត្រ ១៨% បញ្ហាមេកានិច ៧% បញ្ហាជីវសាស្ត្រ ៧% បញ្ហាវិទ្យាសាស្ត្ររៀបចំការងារ ៧% និងបញ្ហាការងារបន្ថែមម៉ោង ៤% ។ ដោយឡែកសម្រាប់ករណីគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកចំពោះកម្មករនិយោជិត ក្នុងឆ្នាំ២០១៩ កន្លងទៅនេះ បានកើតឡើងចំនួន ១ ៥៥៤ករណី (គ្រោះថ្នាក់ដោយរថយន្តចំនួន ៤៣ករណី, ដោយសារម៉ូតូចំនួន ១ ៤៣៧ករណី, រ៉ឺម៉កចំនួន ៩ករណី, កង់ចំនួន ១២ករណី, និងអ្នកថ្មើរជើងចំនួន ៥៣ករណី) ដែលមានជនរងគ្រោះចំនួន ២ ០០៦ នាក់ បណ្តាលឱ្យស្លាប់ចំនួន ៥០នាក់ របួសធ្ងន់ចំនួន ៣៤១ នាក់ និងរបួសស្រាលចំនួន ១ ៦១៥នាក់។









បើប្រៀបធៀបរយៈពេលដូចគ្នានៅក្នុងឆ្នាំ២០១៨ ធៀបនឹងឆ្នាំ២០១៩ ជាលទ្ធផលក្នុងឆ្នាំ២០១៩ ករណីគ្រោះថ្នាក់ចរាចរណ៍មានការថយចុះចំនួន ១៥៦ករណី ស្មើនឹង ១០% ចំណែកជនរងគ្រោះមានការកើនឡើងចំនួន ១៤៣នាក់ ស្មើនឹង ៧%។

ករណីដែលបង្កឱ្យករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងនេះ គឺបណ្តាលមកពីមូលហេតុចម្បងៗមួយចំនួនដូចជា បើកបរលើសល្បឿនកំណត់ ៣៧% , និងកត្តាមិនគោរពសិទ្ធអាទិភាព ២៣% ជែងក្នុងស្ថានភាពគ្រោះថ្នាក់ ១៨% , បត់ខ្វះការប្រុងប្រយ័ត្ន ៩.២% មិនប្រកាន់ស្តាំ ៨% លក្ខណៈបច្ចេកទេសយានយន្ត ៤% និងកត្តាផ្លូវ ០.៨% ។ ទាក់ទងទៅនឹងបញ្ហាខាងលើនេះ **ឯកឧត្តម អ៊ុក-សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាល បានជំរុញឱ្យក្រុមការងារ ទ.ស.ប.ក. និងក្រុមការងារ ស.ផ.ក. បន្តបង្កើនការផ្សព្វផ្សាយអប់រំបន្ថែមទៀត ដល់កម្មករនិយោជិតនៅតាមបណ្តាសហគ្រាស គ្រឹះស្ថាននានា ឱ្យមានការយល់ដឹងខ្ពស់បន្ថែមទៀតពាក់ពន្ធ័និងស្ថានភាពប្រឈមនេះ ដើម្បីកម្មករនិយោជិតទទួលបាននូវសុខភាពដ៏ល្អប្រសើរគ្រប់ពេលវេលា ក្នុងការជម្រុញដល់ការលើកកម្ពស់ជីវភាពរស់នៅដោយផ្ទាល់ក៏ដូចជារួមចំណែកលើកកម្ពស់វិស័យសេដ្ឋកិច្ចកម្ពុជាឱ្យមានការីកចម្រើនឥតឈប់ឈរ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ ខាងលើ មានវត្តមានចូលរួមពីតំណាងក្រសួង ស្ថាប័ន អង្គភាព សហជីព តំណាងរោងចក្រ និងអង្គការពាក់ព័ន្ធនានា សរុបប្រមាណជាង ១៥០នាក់៕








# ឯកឧត្តម អ៊ុក សមវិទ្យា បានដឹកនាំគណៈប្រតិភូទៅចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារ ស្តីពី "ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងសមាគមសន្តិសុខសង្គមអាស៊ាន និងសមាគមសន្តិសុខសង្គមអន្តរជាតិ"

តបតាមការអញ្ជើញរបស់ លោកស្រី Nguyen Thi Minh អគ្គនាយកនៃអង្គភាពសន្តិសុខសង្គមវៀតណាម ចាប់ពីថ្ងៃទី ២០-២២ ខែកុម្ភៈ ឆ្នាំ២០២០ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជា បានដឹកនាំគណៈប្រតិភូទៅចូលរួមក្នុងកិច្ចប្រជុំពិភាក្សាការងារស្តីពី "ការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងសមាគមសន្តិសុខសង្គមអាស៊ាន និងសមាគមសន្តិសុខសង្គមអន្តរជាតិ" ដ៏សំខាន់មួយនៅទីក្រុងហាណូយ សាធារណៈរដ្ឋសង្គមនិយមវៀតណាម។

សមាសភាពនៃការចូលរួមនៃកិច្ចប្រជុំរួមមានតំណាងសមាគមសន្តិសុខសង្គមអាស៊ាន តំណាងសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) អង្គភាពសន្តិសុខសង្គម នៃប្រទេសវៀតណាម បេឡាជាតិសន្តិសុខសង្គម នៃប្រទេសកម្ពុជា តំណាងអង្គការអន្តរជាតិខាងការងារ (ILO) តំណាងធនាគារពិភពលោក (WB) និងតំណាងអង្គការសុខភាពពិភពលោក (WHO)។










កិច្ចប្រជុំពិភាក្សាខាងលើ ផ្តោតសំខាន់លើប្រធានបទមួយចំនួនដូចជា៖

១- ការទទួលស្គាល់នូវការតាំងចិត្តរបស់ ASSA ដើម្បីដាក់បញ្ចូលសកម្មភាពរបស់ ASSA ទៅក្នុងក្របខ័ណ្ឌសកម្មភាពផ្លូវការរបស់អាស៊ាន ក្នុងគោលបំណងបង្រួបបង្រួមសកម្មភាពក្នុងតំបន់រួម ស្តីពីការអភិវឌ្ឍគោលនយោបាយ និងការអនុវត្តសន្តិសុខសង្គម។

២- ការចែករំលែកព័ត៌មាន ដែលអនុញ្ញាតឱ្យអ្នកតំណាងអង្គភាពជាសមាជិក ASSA អាចចូលរួមឬរៀបចំសន្និសីទ និងសកម្មភាពនានានៅក្នុងឆ្នាំ ២០២០ ស្តីពី ខ្លឹមសារនៃសុខុមាលភាព និងសន្តិសុខសង្គមក្នុងក្របខ័ណ្ឌនៃសសរស្តម្ភសង្គម និងវប្បធម៌របស់សហគមន៍អាស៊ាន។

៣- ជំរុញឱ្យសមាជិក ASSA ធ្វើសមាហរណកម្មសកម្មភាពនានា ដើម្បីសម្រេចបានគោលដៅសហស្សវត្សរ៍ដែលបានកំណត់ដោយអង្គការសហប្រជាជាតិ។

សូមបញ្ជាក់ផងដែរថា៖ ក្នុងកំឡុងពេលនៃការចូលរួមកិច្ចប្រជុំខាងលើនេះ **ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តល់បទសម្ភាសជាមួយទូរទស្សន៍ជាតិវៀតណាម (VTV) ដែលពាក់ព័ន្ធទៅនឹងបទពិសោធន៍ ក្នុងការអនុវត្តប្រព័ន្ធសន្តិសុខសង្គមមួយចំនួននៅកម្ពុជា ទាំងនៅពេលបច្ចុប្បន្ន ក៏ដូចជានៅពេលអនាគតផងដែរ៕









# ឯកឧត្តម អ៊ុក សមវិទ្យា កោតសរសើរពីនារី ប.ស.ស. ដែលបានខិតខំបំពេញការងារយ៉ាងល្អក្នុងពេលកន្លងមក



ក្នុងឱកាសអបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៩ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២០ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០នេះ ស្ថិតនៅក្នុងសាលប្រជុំធំនៃ ប.ស.ស. **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. បានកោតសរសើរពីនារី ប.ស.ស. ដែលបានខិតខំបំពេញការងារយ៉ាងល្អក្នុងពេលកន្លងមក។

**ឯកឧត្តម អ៊ុក សមវិទ្យា** បានបញ្ជាក់ថា៖ ស្ត្រីកម្ពុជា ជាថ្នាក់ដឹកនាំក្នុងស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា និងស្ថាប័នក្រសួងមន្ទីរនានារបស់រាជរដ្ឋាភិបាលកំពុងត្រូវបានមើលឃើញថា មានការយកចិត្តទុកដាក់ និងលើកកម្ពស់ពីតួនាទីរបស់ខ្លួនជាបន្តបន្ទាប់។ ដោយឡែកនារី នៅបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ៦៩៦នាក់ ស្មើនឹង ៤៤.២% មានការកើនឡើង ០.២% ប្រៀបធៀបនឹងឆ្នាំ២០១៩ ។ ប.ស.ស. តែងតែគាំទ្របើកទូលាយ និងលើកទឹកចិត្តនារីឱ្យចូលរួមបម្រើការងារ។





**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ ឯកឧត្តមនឹងព្យាយាមធ្វើយ៉ាងណា ជម្រុញឱ្យមានស្ត្រីច្រើនជាងមុនក្នុងការបម្រើការងារក្នុង ប.ស.ស. និងមានការបង្កើនមន្ត្រី និងបុគ្គលិកជាថ្នាក់ដឹកនាំឱ្យបានច្រើនជាងមុនផងដែរ ព្រមទាំងបានសំណូមពរឱ្យមន្ត្រីនិងបុគ្គលិករបស់ខ្លួនខិតខំប្រឹងប្រែងធ្វើការងារ និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឱ្យបានជាប្រចាំ ដើម្បីធ្វើយ៉ាងបម្រើសេវា ប.ស.ស. ជូនសមាជិក ប.ស.ស. ឱ្យបានទាន់ពេលវេលា។

បន្ថែមពីនេះទៀត **ឯកឧត្តម** ប្រតិភូបានបន្តថា៖ ស្ថិតក្រោមប្រធានបទជាសាកល នារីមិនត្រឹមតែផ្តោតសំខាន់លើការប្រគល់សិទ្ធិអំណាច សិទ្ធិសេរីភាពពេញលេញរបស់នារីក្នុងការសម្រេចចិត្ត ការទទួលបានសុភមង្គលនិងការលុបបំបាត់ចោលនៃភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែនារីកន្លងមកក៏បានដើរតួនាទីដ៏សំខាន់ក្នុងការដឹកនាំកិច្ចការធំៗរបស់ប្រទេសថែមទៀតផង៕











# ប.ស.ស. នៅបន្តខិតខំធ្វើយ៉ាងណាបម្រើសេវាសន្តិសុខសង្គមជូនបងប្អូនជាសមាជិករបស់ខ្លួន ឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់

នៅថ្ងៃពុធ ទី១១ ខែមីនា ឆ្នាំ២០២០នេះ នៅសាលប្រជុំធំ នៃ ប.ស.ស. ស្នាក់ការកណ្តាលរាជធានីភ្នំពេញ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម បានអញ្ជើញជាធិបតីភាពក្នុងកិច្ចប្រជុំផ្ទៃក្នុងមួយជាមួយថ្នាក់ដឹកនាំជាប្រធាន និងអនុប្រធាន តាមបណ្តាការិយាល័យ និងប្រធាន ប.ស.ស. សាខាខណ្ឌ ទាំងអស់នៃ ប.ស.ស. សរុបប្រមាណជាង ៤០នាក់ ដើម្បីត្រួតពិនិត្យលើបញ្ហាប្រឈម និងចំណុចមិនប្រក្រតីនានា ដែលជាកត្តារាំងស្ទះនៃការផ្តល់ និងទទួលប្រើប្រាស់សេវារបស់បងប្អូនដែលជាសមាជិក ប.ស.ស.។







**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល នៅក្នុងឱកាសនេះ បានជម្រុញបន្ថែមឱ្យ លោក លោកស្រី ជាប្រធាន អនុប្រធាន និងមន្ត្រី ប.ស.ស. គ្រប់ការិយាល័យ និងគ្រប់សាខាទាំងអស់ធ្វើយ៉ាងណា ពន្លឿនក្នុងការផ្តល់ប្រាក់បំណាច់ប្រចាំថ្ងៃ និងប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលសម្រាប់សមាជិកប.ស.ស. ជាស្ត្រីសម្រាលកូនឱ្យទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការផ្តល់ការសម្របសម្រួលឱ្យបានទាន់ពេលវេលាចំពោះបងប្អូនដែលជាសមាជិកទៅទទួលសេវានៅតាមមូលដ្ឋានសុខាភិបាលដែលជាដៃគូ ប.ស.ស.។

**ឯកឧត្តម** ប្រតិភូរាជរដ្ឋាភិបាល បានថ្លែងបន្តទៀតថា៖ ក្នុងនាមយើងជាមន្ត្រីរាជការ ត្រូវធ្វើយ៉ាងណាបម្រើសេវាជូនបងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិតឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនិងគោលនយោបាយជាតិគាំពារសង្គមរបស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធិភាពខ្ពស់។ រហូតមកដល់ពេលនេះ ស្ថាប័ន ប.ស.ស. ត្រូវបានប្រមុខរាជរដ្ឋាភិបាលទទួលស្គាល់ និងវាយតម្លៃខ្ពស់ចំពោះការបំពេញភារកិច្ចរបស់ខ្លួនបានយ៉ាងល្អប្រសើរនិងទាន់ពេលវេលានូវសេវាកិច្ចគាំពារសង្គម ជាពិសេសការផ្តល់សេវារបបសន្តិសុខសង្គម សម្រាប់បងប្អូនកម្មការិនីជាស្ត្រីសម្រាលកូន៕













# បេឡាជាតិសន្តិសុខសង្គម នឹងដាក់ឱ្យអនុវត្តនូវ របបសន្តិសុខសង្គមផ្នែកប្រាក់សោធននៅពេលឆាប់ៗខាងមុខ

នេះជាលើកទី៤ហើយ ដែលបេឡាជាតិសន្តិសុខសង្គម រៀបចំកិច្ចប្រជុំ "របបសន្តិសុខសង្គមផ្នែកប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ"។

**ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងបេឡាជាតិសន្តិសុខសង្គម បានថ្លែងឱ្យដឹងថា៖ ការបង្កើតឱ្យមានរបបសន្តិសុខសង្គមផ្នែកប្រាក់សោធននេះឡើង គឺដើម្បីការពារហិរញ្ញវត្ថុពលរដ្ឋពេលចាស់ជរា តាមរយៈការផ្តល់ប្រាក់ចំណូលសមរម្យចំពោះប្រជាជនដែលបានចូលរួមក្នុងរបបប្រាក់សោធន ដោយបញ្ឈប់នូវទម្លាប់ចិញ្ចឹមគ្នាទៅវិញទៅមក ដែលធ្វើឱ្យបន្ទុកចំណាយក្នុងគ្រួសារកាន់តែមានការកើនឡើង ជាហេតុធ្វើឱ្យជីវភាពគ្រួសារ នៃប្រជាជនកម្ពុជាកាន់តែធ្លាក់ចុះ។ កន្លងមកបេឡាជាតិសន្តិសុខសង្គម បានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងថែទាំសុខភាពរួចមកហើយ របបទាំងពីរនេះក៏បានជួយសម្រាលបន្ទុកយ៉ាងច្រើនដល់ និយោជិតនៃវិស័យឯកជន ក៏ដូចជាមន្ត្រីរាជការនៅពេលជួបប្រទះហានិភ័យផ្សេងៗ កើតឡើងជាយថាហេតុកន្លងមក។ ដោយមានការខិតខំប្រឹងប្រែងពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ប.ស.ស. គ្រោងនឹងដាក់ឱ្យដំណើរការ "របបប្រាក់សោធន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ" កម្ពុជានៅពេលឆាប់ៗខាងមុខនេះ ដើម្បីជួយសម្រាលបន្ទុកដល់ បងប្អូនប្រជាពលរដ្ឋ ពិសេសបងប្អូនកម្មករនិយោជិត នៅពេលចាស់ជរា និងខ្វះលទ្ធភាពស្វែងរកប្រាក់ចំណូល។





**ឯកឧត្តម ស៊ុំ សោភ័ណ** សង្ឃឹមជឿជាក់ថា៖ បន្ទាប់ពីបញ្ចប់សិក្ខាសាលាពិគ្រោះយោបល់ នេះ សិក្ខាកាមទាំងអស់នឹងចូលរួមចំណែកយ៉ាងសកម្ម ដើម្បីផ្តល់ជាធាតុចូលសំខាន់ៗជាច្រើនបន្ថែមទៀត ដើម្បីឱ្យការអនុវត្តរបបប្រាក់សោធនសម្រាប់វិស័យឯកជន នៅកម្ពុជាកាន់តែមានលក្ខណៈល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមបញ្ជាក់ថា៖ សិក្ខាសាលាពិគ្រោះយោបល់ខាងលើប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ស៊ុំ សោភ័ណ** នាយករងបេឡាជាតិសន្តិសុខសង្គម ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. នៅថ្ងៃអង្គារ ទី២១ ខែមករា ឆ្នាំ២០២០ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ដោយមានវត្តមានចូលរួមពីសហព័ន្ធនិយោជក សហព័ន្ធសហជីពកម្ពុជា អង្គការដៃគូអភិវឌ្ឍ និងស្ថាប័ន អង្គភាពពាក់ព័ន្ធនានា សរុបប្រមាណជា ១៥០នាក់៕











# កិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោងកិច្ចគាំពារសង្គម “ ផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ SPIN Project

**ឯកឧត្តមវេជ្ជបណ្ឌិត ស៊ុំ សោភ័ណ** នាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ិត សមហិញ្ញា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក បេឡាជាតិសន្តិសុខសង្គម ក្នុងកិច្ចប្រជុំគណៈកម្មការសម្របសម្រួលគម្រោងកិច្ចគាំពារសង្គម “ផ្នែកនវានុវត្តន៍សម្រាប់វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (SPIN Project)” នៅថ្ងៃព្រហស្បតិ៍ ទី១២ ខែមីនា ឆ្នាំ២០២០ នេះ បានបញ្ជាក់ថា នេះគឺជាកិច្ចប្រជុំលើកទី២ហើយ របស់គណៈកម្មការសម្របសម្រួលនៃគម្រោងកិច្ចគាំពារសង្គម ដោយផ្តោតសំខាន់ទៅលើការកែសម្រួលអំពីនីតិវិធីសំខាន់ៗចំនួន ៣ គឺ៖ ១.ការកំណត់អត្តសញ្ញាណ ២.ការចុះបញ្ជិកា និង ៣.ការប្រមូលភាគទានសម្រាប់ប្រជាជន ក្រុមគោលដៅដែលជាកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដោយជ្រើសយកអ្នកបើកម៉ូតូរ៉ឺម៉ក និងអ្នកបម្រើក្នុងផ្ទះជាអាទិភាពដំបូង ហើយនឹងបន្តទៅដល់កម្មករសំណង់ដែលជាអាទិភាពបន្ទាប់ផងដែរ។

កាលពីកិច្ចប្រជុំលើកទី១ យើងបានសិក្សាលើសមិទ្ធិលទ្ធភាពលើការអនុវត្តគម្រោង ប៉ុន្តែពេលនេះ គឺជាជំហានបន្ទាប់ដែលត្រូវពិនិត្យកែសម្រួលលើនីតិវិធីសំខាន់ៗទាំង ៣ចំណុចដើម្បីធានាឱ្យមានសមធម៌ សាមគ្គីធម៌សង្គម និងលើកកម្ពស់សុខុមាលភាព ជីវភាពរបស់ប្រជាពលរដ្ឋ។





ទាក់ទងទៅនឹងការកែសម្រួលអំពីនីតិវិធីសំខាន់ៗចំនួន៣ ខាងលើ **ឯកឧត្តម វេជ្ជបណ្ឌិត** បានបញ្ជាក់ទៀតថា៖ ដើម្បីធានាឱ្យបាននូវសង្គតិភាពសង្គម និងជៀសវាងហានិភ័យហិរញ្ញវត្ថុដល់ប្រជាជនគ្រប់រូប ប.ស.ស. បានធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងតំណាងកម្មករនិយោជិត ដើម្បីសិក្សាលើសមិទ្ធិលទ្ធភាពលើការអនុវត្តកិច្ចគាំពារសង្គមដល់កម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធទៅលើប្រជាជន ក្រុមគោលដៅដែលរួមមានអ្នកបើកម៉ូតូរ៉ឺម៉ក និងអ្នកបម្រើក្នុងផ្ទះជាអាទិភាព ហើយនិងបន្តទៅដល់កម្មករសំណង់ដែលជាអាទិភាពបន្តបន្ទាប់ផងដែរ។

**ឯកឧត្តមវេជ្ជបណ្ឌិត** សង្ឃឹមយ៉ាងមុតមាំថា កិច្ចប្រជុំនេះ នឹងជួយផ្តល់គណៈកម្មការសម្របសម្រួលនូវធាតុចូលសំខាន់ៗ បទពិសោធន៍ថ្មីៗ និងដំណោះស្រាយបញ្ហាប្រឈម ដែលកំពុងមានចំពោះមុខ ដើម្បីជាគន្លឹះ និងឧបករណ៍ក្នុងការសម្រេចឱ្យបាននូវគម្រោងកិច្ចគាំពារសុខភាពសង្គមផ្នែកនវានុវត្តន៍សម្រាប់ វិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ (**SPIN-Project**) ។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំពិភាក្សាខាងលើ ប្រព្រឹត្តទៅនៅសាលប្រជុំធំ នៃទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយវត្តមានចូលរួមពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ សមាគមអ្នកបម្រើតាមផ្ទះ អង្គការអន្តរជាតិខាងការងារប្រចាំប្រទេសកម្ពុជា (ILO) ក្រុមការងារបច្ចេកទេសនៃគម្រោង SPIN ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) និងអង្គភាព អង្គការពាក់ព័ន្ធនានាសរុបប្រមាណជាង ៥០នាក់ ៕












# បេឡាជាតិសន្តិសុខសង្គម បន្តពង្រឹងការអនុវត្តរបបសន្តិសុខសង្គម សម្រាប់កម្មករនិយោជិត និងមន្ត្រីសាធារណៈ

**ឯកឧត្តម ឌុយ ប៊ុនសេរីវឌ្ឍមុនី** អភិបាលរងនៃគណៈអភិបាលខេត្តក្រចេះ និង **ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយនៃការអនុវត្តរបបសន្តិសុខសង្គម ដល់មន្ទីរ អង្គភាព ម្ចាស់សហគ្រាស គ្រឹះស្ថាន ព្រមទាំងស្ថាប័នពាក់ព័ន្ធ។

**ឯកឧត្តម** អភិបាលរងខេត្ត បានកោតសរសើរចំពោះ បេឡាជាតិសន្តិសុខសង្គម ដែលខិតខំអនុវត្តការងាររបស់ខ្លួន ប្រកបដោយស្មារតី ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងសំណូមពរដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន ទាំងអស់ត្រូវចុះបញ្ជិកាជាមួយ ប.ស.ស. បង់ភាគទានឱ្យទាន់ពេលវេលាដើម្បីកុំឱ្យបាត់អត្ថប្រយោជន៍ ហើយចូលរួមអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យមានប្រសិទ្ធភាពខ្ពស់។ អង្គភាព មន្ទីរ អាជ្ញាធរពាក់ព័ន្ធទាំងអស់នៅក្នុងខេត្តត្រូវចូលរួមសហការជាមួយ ប.ស.ស. ក្នុងការអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព ក្នុងការរួមចំណែក អភិវឌ្ឍន៍សង្គមជាតិយើងឱ្យមានការរីកចម្រើន និងសុខដុមរមនា។








**ឯកឧត្តម ម៉េង ហុង** នាយករង ប.ស.ស. មានប្រសាសន៍ថា៖ បច្ចុប្បន្ន ប.ស.ស. បាននឹងកំពុងដំណើរការរបបសន្តិសុខសង្គមចំនួនពីរ គឺផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ដូច្នេះបងប្អូនកម្មករនិយោជិតទាំងអស់ជាសមាជិក ប.ស.ស. អាចទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺនៅគ្រប់មន្ទីរពេទ្យទាំងអស់ (មន្ទីរពេទ្យរដ្ឋ និងមន្ទីរពេទ្យឯកជន) ជាដៃគូជាមួយ ប.ស.ស. ដោយឥតគិតថ្លៃ។ ប.ស.ស. បាននឹងកំពុងរៀបចំគោលនយោបាយនានា និងអនុក្រឹត្យដាក់ឱ្យដំណើរការផ្នែកប្រាក់សោធន ដើម្បីឱ្យបងប្អូនកម្មករនិយោជិតទាំងអស់ទទួលបានប្រាក់ចូលនិវត្តន៍ដូចទៅនឹងមន្ត្រីរាជការផងដែរ។

**ឯកឧត្តម** នាយករង បានបន្តទៀតថា៖ គិតមកដល់ឆ្នាំ ២០១៩ ប.ស.ស. បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់ជនរងគ្រោះជាកម្មករនិយោជិតចំនួន ២២២ ៩៣៦នាក់ ក្នុងចំណោមកម្មករនិយោជិតជាសមាជិកចំនួន ១ ៦៦០ ៤៦៤នាក់។ ដោយឡែក សម្រាប់ផ្នែកថែទាំសុខភាព បានផ្តល់សេវាដល់កម្មករនិយោជិតចំនួន ៣ ២៦៥ ៤៥០ ដង/នាក់ ក្នុងចំណោមកម្មករ-និយោជិតប្រមាណជាង ២ ០៩៩ ៣៨២ នាក់ ក្នុងនោះផងដែរ បេឡាជាតិសន្តិសុខសង្គម បានចុះបញ្ជីមន្ត្រីសាធារណៈ អតីត-មន្ត្រីរាជការ និងអតីតយុទ្ធជន សរុបចំនួន ៣៦ក្រសួង ស្មើនឹង ៣៣៨ ៥០៨ នាក់ (មន្ត្រីរាជការចំនួន ២២៣ ៨៨៤ នាក់ អតីត-មន្ត្រីរាជការ ចំនួន ៥៦ ២៣៥នាក់ និងអតីតយុទ្ធជនចំនួន ៥៨ ៣៨៩ នាក់) និងបានផ្តល់សេវាចំនួន ៩៥ ៣០៥ ករណី/ដងនាក់។

សូមបញ្ជាក់ថា៖ កិច្ចប្រជុំខាងលើ ធ្វើឡើងនៅថ្ងៃចន្ទ ទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ សាលប្រជុំមហាស្រព ខេត្តក្រចេះ ដោយមានអ្នកចូលរួមប្រមាណជា ២០០នាក់៕







# អ្នកបើកបរយានយន្តដឹកកម្មករ និងបងប្អូនកម្មករ-កម្មការិនី ប្រមាណជិត៤០០នាក់ សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិតចូលរួមស្វែងយល់ច្បាប់ ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក

នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយអប់រំច្បាប់ស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធានការិយាល័យគោលនយោបាយ នៃបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម ជាសមាជិកគណៈ-កម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជាប្រធានក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក សម្រាប់គាំពារកម្មករនិយោជិត -(ស.ផ.ក) នៃ ប.ស.ស. **ឯកឧត្តម** បានថ្លែងថា៖ ករណីគ្រោះថ្នាក់ចរាចរណ៍ នៅតែបន្តកើតមានឡើងលើកម្មករនិយោជិត នៅ-ពេលធ្វើដំណើរ ឬដោយមធ្យោបាយផ្សេងៗ ក្នុងនោះរថយន្តដឹកកម្មករនិយោជិតមួយចំនួន ត្រូវបានកែច្នៃចេញពីរថយន្តដឹកទំនិញទៅជារថយន្តដឹកកម្មករ ជាហេតុធ្វើឱ្យមិនស្របទៅតាមលក្ខណៈ បច្ចេកទេស។ បន្ថែមពីលើនេះ **ឯកឧត្តម** បានសំណូមពរដល់អ្នកបើកបររថយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិតទាំងអស់ ត្រូវគោរពច្បាប់ចរាចរណ៍ ជាពិសេសគោរពទៅលើសីលធម៌ ១០ចំណុច ព្រមទាំងពាក់មួកសុវត្ថិភាព ក្នុងពេលធ្វើដំណើរជាប់ជានិច្ច។





**ឯកឧត្តម ព្រាប ច័ន្ទវិបុល** ទីប្រឹក្សាផ្នែកសុវត្ថិភាពចរាចរណ៍ ក៏បានអំពាវនាវ ដល់បងប្អូនអ្នកបើកបររថយន្តដឹកកម្មករ និងបងប្អូនកម្មករនិយោជិតទាំងអស់ ធ្វើយ៉ាងណាត្រូវ៖

- ចូលរួមគោរព និងអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកឱ្យបានខ្ជាប់ខ្ជួន និងគ្រប់ៗគ្នា
- សម្រាប់ឡានដឹកកម្មករ មិនត្រូវផ្ទុកកម្មករលើសចំណុះ
- ត្រួតពិនិត្យយានយន្តមុនពេលចេញទៅដឹកកម្មករ
- ឆៀករថយន្តជាប្រចាំ
- អ្នកបើកបររថយន្តដឹកកម្មករទាំងអស់ ត្រូវទៅប្រឡងយកបណ្ណ៍បើកបរឱ្យស្របតាមប្រភេទយាន
- ចូលរួមវគ្គបណ្តុះបណ្តាលរបស់ក្រុមការងារ ប.ស.ស. ស្តីពីច្បាប់ចរាចរណ៍ផ្លូវគោក។





ថ្ងៃសុក្រ ១៥រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០២០ នៅតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត ខេត្តស្វាយរៀង ដោយមានវត្តមានចូលរួមពីសំណាក់ **ឯកឧត្តម ហេង សុផាន់ណារិទ្ធ** ប្រធាន ការិយាល័យគោលនយោបាយ ជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ិត សមហិទ្ធ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយក ប.ស.ស. **ឯកឧត្តម ព្រាប ច័ន្ទវិបុល** ទីប្រឹក្សាផ្នែកសុវត្ថិភាពចរាចរណ៍ ព្រមទាំងមានការចូលរួមពីតំណាង ស្ថាប័ន មន្ទីរ តំណាងរោងចក្រ អង្គភាពពាក់ព័ន្ធនានា និងបងប្អូនអ្នកបើកបររថយន្តដឹកកម្មករនិយោជិត និងកម្មករ-កម្មការិនី សរុបជិត ៤០០នាក់៕





# ថ្នាក់ដឹកនាំ នៃបេឡាជាតិសន្តិសុខសង្គម ចូលរួមសន្និសីទស្តីពីពានរង្វាន់ព្រះអង្គម្ចាស់ MAHIDOL ក្រោមប្រធានបទ "ការពន្លឿនវឌ្ឍនភាពដើម្បីឆ្ពោះទៅការគ្របដណ្តប់សុខភាពសកល (Universal Health Coverage)

នៅក្នុងសន្និសីទស្តីពីពានរង្វាន់ព្រះអង្គម្ចាស់ MAHIDOL នៅទីក្រុងបាងកកប្រទេសថៃ ប្រតិភូជាថ្នាក់ដឹកនាំ ប.ស.ស. ក្រោមការចាត់តាំងពីសំណាក់ **ឯកឧត្តម អ៊ុក សមវិទ្យា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម-(ប.ស.ស.) ទៅចូលរួមសិក្សាស្វែងយល់ និងពិភាក្សាលើប្រធានបទ "ការពន្លឿនវឌ្ឍនភាពដើម្បីឆ្ពោះទៅការគ្របដណ្តប់សុខភាពសកល (Universal Health Coverage)" ។ តាមការបញ្ជាក់ប្រាប់ពីសំណាក់ថ្នាក់ដឹកនាំបេឡាជាតិសន្តិសុខសង្គមបានឱ្យដឹងថាសន្និសីទ-ខាងលើ គឺផ្តោតទៅលើការពិភាក្សានូវចំណុចសំខាន់ៗចំនួន ៦ រួមមាន ៖

១.វឌ្ឍនភាពស្តីពីគោលដៅនៃការគ្របដណ្តប់សុខភាពសកល (UHC Goals) និងបញ្ហាប្រឈមសម្រាប់ទសវត្សបន្ទាប់ នៅក្នុងបរិបទនៃនិន្នាការសកល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

២.អភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាលដែលផ្តោតលើការថែទាំសុខភាពបឋមប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ដើម្បី-ឆ្លើយតបតំរូវការរបស់ប្រជាពលរដ្ឋ។

៣.ផ្លាស់ប្តូរគំរូនៃការផ្តល់សេវាកម្ម និងអនុវត្តយុទ្ធសាស្ត្របង្កើនគុណភាពនៃការផ្តល់សេវាសុខាភិបាល ។

៤.អនុវត្ត និងបង្កើននូវគោលការណ៍ និងយុទ្ធសាស្ត្រស្នូលនៃហិរញ្ញប្បទានសុខាភិបាលសម្រាប់ការគ្របដណ្តប់សុខភាពសកល ។

៥.ជំរុញឱ្យមានទំនួលខុសត្រូវបែបសង្គម និងសមធម៌ដើម្បីបង្កើននវានុវត្តន៍នៅក្នុងបច្ចេកវិទ្យាផ្នែកវេជ្ជសាស្ត្រ សុខភាពឌីជីថល ការផ្តល់សេវានិងហិរញ្ញប្បទានសុខាភិបាលដែលជួយពន្លឿនវឌ្ឍនភាពដើម្បីឆ្ពោះទៅដល់គោលដៅការគ្របដណ្តប់សុខភាពសកល។

៦.ពង្រឹងភាពជាអ្នកដឹកនាំ និងគណនេយ្យភាពដើម្បីពន្លឿនវឌ្ឍនភាពដើម្បីឆ្ពោះទៅដល់គោលដៅការគ្របដណ្តប់សុខភាព-សកល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងតួនាទីនៃអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិលក្នុងការពាំនាំពីការប្តេជ្ញាចិត្តទៅជាសកម្មភាព។

សន្និសីទស្តីពីពានរង្វាន់ព្រះអង្គម្ចាស់ MAHIDOL ខាងលើនេះ ត្រូវបានរៀបចំឡើងក្រោមការសហការ និងគាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តជាតិជប៉ុន( JICA ) ដែលប្រព្រឹត្តទៅរយៈពេល ៦ថ្ងៃ គឺចាប់ពីថ្ងៃទី២៨ ខែមករា ដល់ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានការចូលរួមពីបណ្តា អង្គភាព/ស្ថាប័ន ពាក់ព័ន្ធទៅនឹងវិស័យសុខាភិបាល នៃបណ្តាប្រទេសក្នុង-តំបន់ និងអន្តរជាតិ សរុបប្រមាណជាង ១០០០នាក់ នៅទីក្រុងបាងកក ប្រទេសថៃ៕



# អាហារទាំងប៉ុន្មានប្រភេទនេះ ជាប្រភពនៃប្រូតេអ៊ីន

ប្រូតេអ៊ីនអាចជួយសម្រកទម្ងន់-និងជួយឱ្យយើងឆ្អែតបានយូរទៀតផង។ ប៉ុន្តែយើងត្រូវជ្រើសរើសប្រូតេអ៊ីនឱ្យបានត្រឹមត្រូវ និងញ៉ាំក្នុងកម្រិតត្រឹមត្រូវដើម្បីទទួលបានប្រយោជន៍ដល់សុខភាព។

**១. គ្រឿងសមុទ្រ**

គ្រឿងសមុទ្រជាប្រភពនៃប្រូតេ-អ៊ីនព្រោះគ្រឿងសមុទ្រមានជាតិខ្លាញ់-ទាប។ ដោយឡែកត្រីសាល់ម៉ុនគឺមាន-ជាតិខ្លាញ់រាងច្រើនបន្តិច ប៉ុន្តែខ្លាញ់នេះគឺល្អសម្រាប់សុខភាពដែលជាអាស៊ីដ-ខ្លាញ់អូមេហ្គា៣។

**២. សាច់បក្សីពណ៌ស**

យើងគួរញ៉ាំសាច់បក្សីពណ៌សដូចជាសាច់មាន់ជាដើមដើម្បីទទួលបានប្រូ-តេអ៊ីន។សម្រាប់សាច់ពណ៌ក្រម៉ៅគឺមានជាតិខ្លាញ់ច្រើនបន្តិច។ស្បែករបស់សាច់-បក្សីសំបូរដោយជាតិខ្លាញ់ឆ្អែត ដូចនេះយកល្អពេលញ៉ាំគួរយកស្បែកចេញ។

**៣. ទឹកដោះគោ ឈីស និងយ៉ាអួ**

ផលិតផលធ្វើពីទឹកដោះគោដូច-ជាទឹកដោះគោ ឈីស និងយ៉ាអួមិនត្រឹម-តែមានប្រូតេអ៊ីនទេ តែនៅផ្ទុកកាល់ស្យូម និងវីតាមីន Dទៀត។ យើងអាចជ្រើស-រើសផលិតផលទឹកដោះគោ ដែលមានជាតិខ្លាញ់តិចឬគ្មានជាតិខ្លាញ់ដើម្បីជួយឱ្យឆ្អឹង និងធ្មេញរឹងមាំ និងបង្ការជំងឺពុក-ឆ្អឹងផងដែរ។

**៤. ស៊ុត**

ស៊ុតជាប្រភពប្រូតេអ៊ីនដែលមានតម្លៃសមរម្យបំផុត។ សមាគមជំងឺបេះដូងអាមេរិកបាននិយាយថាមនុស្សពេញវ័យអាចញ៉ាំស៊ុតមួយគ្រាប់មួយថ្ងៃ។

**៥. សណ្តែក**

សណ្តែក ២០០ក្រាមផ្តល់នូវប្រូ-តេអ៊ីនរុក្ខជាតិស្មើនឹងសាច់គោអាំង២៨-,៣៥ក្រាម។ បន្ថែមពីនេះទៀត ពពួក-សណ្តែកនេះមានតម្លៃសមរម្យនិងសំបូរដោយជាតិសរសៃដែលអាចជួយឱ្យយើងឆ្អែតបានរាប់ម៉ោង។

**៦. សណ្តែកសៀង**

ការញ៉ាំសណ្តែកសៀង៥០ក្រាមរាល់ថ្ងៃអាចបញ្ចុះកូលេស្តេរ៉ូលរហូតដល់៣%។ ម៉្យាងទៀតការទទួលបានប្រូតេ-អ៊ីនរុក្ខជាតិពីសណ្តែកជំនួសឱ្យការទទួលបានប្រូតេអ៊ីនពីប្រភពមានជាតិខ្លាញ់ និងការរក្សារបបអាហារល្អអាចជួយដល់សុខ-ភាពបេះដូង។

**៧. សាច់គោគ្មានខ្លាញ់**

សាច់គោគ្មានខ្លាញ់មានជាតិខ្លាញ់ឆ្អែតច្រើនជាងសាច់ទ្រូងមាន់អត់មាន-ស្បែកប្រហែល២ក្រាម។សាច់គោគ្មានខ្លាញ់ក៏ជាប្រភពដ៏ល្អនៃស័ង្កសី ជាតិដែក-និងវីតាមីន B12។

# កាត់បន្ថយហានិភ័យពីការឆ្លងជំងឺកូវីដ១៩

World Health Organization

115 ឥតគិតថ្លៃ



លាងដៃឲ្យបានញឹកញាប់ ជាមួយសាប៊ូនិងទឹកស្អាត
ឬទឹកអាល់កុលលាងដៃឬ អាល់កុលហ៊្សែល

ក្អកឬកណ្ដាស់ ប្រើកែងដៃរបស់អ្នកខ្ទប់មាត់
និងច្រមុះ - មិនមែនប្រើបាតដៃរបស់អ្នកទេ!





ជៀសវាងប៉ះពាល់ ភ្នែក ច្រមុះ ឬ មាត់

កាត់បន្ថយការជួបជុំក្នុងសង្គម
និងការចំណាយពេលវេលានៅកន្លែងប្រមូលផ្ដុំ។





ជៀសវាងប៉ះពាល់ជិតស្និទ្ធជាមួយអ្នកមានជំងឺផ្លូវដង្ហើម
ស្រួចដូចជា គ្រុនក្ដៅ ក្អក កណ្ដាស់ ឬ ផ្ដាសាយ

សម្អាតនិងសម្លាប់មេរោគលើវត្ថុ
និងលើផ្ទៃឲ្យបានញឹកញាប់



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ :....៤០៤.........ព.មប្រក

ថ្ងៃ.ចន្ទ ៩កើត... ខែ.កត្តិក..... ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ, ថ្ងៃទី..០៧.....ខែ.តុលា......ឆ្នាំ២០១៩

# ប្រកាស
# រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦/០៩/១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨/០៦/១៨ ប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៨៩៥/០៧ ចុះថ្ងៃទី០១ /០៩/៩៥ ប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៤ ចុះថ្ងៃទី២៤/០១/៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០/អនក្រ.បក ចុះថ្ងៃទី០៥/០៨/៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១/អនក្រ.បក ចុះថ្ងៃទី១៣/០៧/០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាលនិងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ របស់ក្រសួងព័ត៌មាន
- យោងប្រកាសរបស់ក្រសួងព័ត៌មានលេខ ៦២៥/០៩ ព.ម ប្រក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៩ ស្តីពីការអនុញ្ញាតឲ្យបោះពុម្ពផ្សាយព្រឹត្តិបត្រ "បេឡាជាតិរបបសន្តិសុខសង្គម" ដោយមានលោក ជាវ ប៊ុនរិទ្ធ ជាចាងហ្វាងការផ្សាយ ។
- យោងលិខិតស្នើសុំផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់លោក ជាវ ប៊ុនរិទ្ធ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឲ្យផ្ទេរសិទ្ធិអាជីវកម្មព្រឹត្តិបត្រឈ្មោះ "បេឡាជាតិរបបសន្តិសុខសង្គម" ពីលោក ជាវ ប៊ុនរិទ្ធ មកលោក ហេង សុផានណារិទ្ធ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៨៦៨២៨២ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ មានអាសយដ្ឋាននៅផ្ទះ៧៣AE0E1 ផ្លូវ៤៣២ ភូមិ៣ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ជំនួសវិញ ៖

-មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅអាគារលេខ០៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**ប្រការ២** : រាល់ដំណើរការបោះពុម្ពផ្សាយត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពី របបសារព័ត៌មាន ក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន ត្រូវដាក់អាសយដ្ឋានទីចាត់ការព្រឹត្តិបត្រ ឈ្មោះចាងហ្វាងការផ្សាយ និងឈ្មោះអាសយដ្ឋានរោងពុម្ពនៅលើទំព័រព្រឹត្តិបត្ររបស់ខ្លួន ព្រមទាំងយកព្រឹត្តិបត្រ មួយចំនួនមកតម្កល់ទុកនៅនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មាន និងចំនួន០២ច្បាប់ តម្កល់ទុកនៅបណ្ណាល័យជាតិ។

**ប្រការ៣** : ករណីប្រព្រឹត្តល្មើសដូចចែងក្នុងប្រការ១ និងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ៤** : ប្រកាសនេះមានសុពលភាពរយៈពេល ០១(មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

**ប្រការ៥** : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ខុទ្ទកាល័យ នៃក្រសួងព័ត៌មាន មន្ទីរព័ត៌មានរាជធានីភ្នំពេញ និងអាជ្ញាធរដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (អគ្គស្នងការដ្ឋាននគរបាលជាតិ)
- ក្រសួងយុត្តិធម៌
- សាលារាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារព័ត៌មាន
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

# បេឡាជាតិសន្តិសុខសង្គម

## National Social Security Fund

០២៣ ៨៨ ២៤ ៣៤
០២៣ ៩៩ ៨៤ ១៧
០២៣ ៩៩ ៨៤ ១៨
០២៣ ៩៩ ៨៨ ១៩
០២៣ ៨៨ ២៦ ២៣

បេឡាជាតិរបបសន្តិសុខសង្គម
NSSF Official
www.nssf.gov.kh
info@nssf.gov.kh

អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
( បរិវេណក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)

